**ផែនការបង្រៀន (រយៈពេល ០១ថ្ងៃ)**

**វគ្គបំប៉នស្តីពី វិធីសាស្ត្របង្រៀនថ្មី៖ ការសិក្សាបែបគម្រោង**

New Teaching Methodology: Project based Learning

**របៀបវារៈ**

| ម៉ោង | សកម្មភាព | អ្នកសម្របសម្រួល |
|---|---|---|
| ៧:៣០-៨:០០ | **ការអញ្ជើញមកដល់របស់សិក្ខាកាម និងការចុះឈ្មោះ** | |
| ៨:០០-៨:១៥ | **ពិធីបើកសិក្ខាសាលា** | |
| ៨:១៥-៩:១៥ | **ការយល់ដឹងអំពីការកែទម្រង់ ដំណើរការបង្រៀន និងរៀននៅកម្ពុជា**<br>1. បញ្ហាសំខាន់ៗទាក់ទងនឹង ការវិវត្តគរុកោសល្យនៅកម្ពុជា<br>2. ការយល់ដឹងពីការអប់រំនៅសតវត្សរ៍ទី ២១<br>3. ការយល់ដឹងអំពី គោលវិធីអប់រំ វិធីសាស្ត្រអប់រំ និងបច្ចេកទេស/ល្បិចអប់រំ<br>4. ការប្រើគោលវិធីបញ្ចូលគ្នា ឬកូនកាត់ក្នុងការបង្រៀននិងការរៀន<br>5. សេចក្តីសន្និដ្ឋានសំខាន់ៗមួយចំនួនដើម្បីការយល់ដឹងថ្មី | លោក អ៊ុល រុន |
| ៩:១៥-៩:៣០ | *សម្រាកពេលព្រឹក* | |
| ៩:៣០-៩:៤៥ | **ការសិក្សាបែបគម្រោង**<br>1. គោលបំណងនៃវគ្គសិក្សា | លោក អ៊ុល រុន |
| ៩:៤៥-១០:០០ | 2. តើរៀនដើម្បីអ្វី? | លោក អ៊ុល រុន |
| ១០:០០-១០:២៥ | 3. តើអ្វីជាការរៀនពិតប្រាកដ? | លោក អ៊ុល រុន |
| ១០:២៥-១១:០០ | 4. តើការសិក្សាបែបគម្រោងជាអ្វី? | លោក អ៊ុល រុន |
| | *សម្រាកអាហារថ្ងៃត្រង់* | |
| ២:០០-២:៤០ | 5. ប្រភេទនៃការសិក្សាបែបគម្រោងដែលគ្រូអាចរៀបចំបាន | លោក អ៊ុល រុន |
| ២:៤០-៣:០០ | 6. ការវាយតម្លៃការសិក្សាបែបគម្រោងរបស់សិស្ស | លោក អ៊ុល រុន |
| ៣:០០-៣:១៥ | 7. ការប្រៀបធៀបរវាងក្លឹបមុខវិជ្ជា និងការសិក្សាបែបគម្រោង | លោក អ៊ុល រុន |
| ៣:១៥-៣:៣០ | *សម្រាកពេលរសៀល* | |
| ៣:៣០-៣:៤៥ | 8. ទស្សនៈទូទៅស្តីពីការបង្រៀនតាមទម្លាប់និងការបង្រៀនបែបបង្កើតថ្មី | លោក អ៊ុល រុន |
| ៣:៤៥-៤:០០ | 9. ការសិក្សាបែបគម្រោងនិងក្លឹបសិក្សានឹងជួយសិស្សអភិវឌ្ឍបំណិននៃការគិតស្របតាមទ្រឹស្តី Bloom Taxonomy | លោក អ៊ុល រុន |
| ៤:០០-៤:៤០ | 10. ការធ្វើផែនការចំពោះការសិក្សាបែបគម្រោងរបស់អ្នក | លោក អ៊ុល រុន |
| ៤:៤០-៥:០០ | កិច្ចការ៖ ការអនុវត្តបង្កើតការសិក្សាបែបគម្រោង | លោក អ៊ុល រុន |

*សម្គាល់៖ សូមរក្សាសិទ្ធិក្នុងការកែប្រែកម្មវិធី ទៅតាមភាពចាំបាច់។*

# ផែនការបង្រៀន

| ម៉ោង | ចំណុចក្នុងសៀវភៅមេរៀន | សកម្មភាពគ្រូវអនុវត្ត | ទំព័រក្នុងមេរៀន |
|---|---|---|---|
| | **ការណែនាំអំពីការងារគម្រោងនិងក្តីបមុខវិជ្ជា**<br><br>**១. គោលបំណង** | ✓ ស្វាគមន៍ដល់សិក្ខាកាមនិងថ្លែងអំណរគុណចំពោះការចូលរួមរបស់ពួកគាត់។<br>✓ អ្នកសម្របសម្រួលណែនាំខ្លួន។<br>✓ គោលបំណងវគ្គ ៖ សួរសិក្ខាកាម ២ទៅ៣នាក់ "**ហេតុអ្វីបានជាយើងជួបជុំគ្នាថ្ងៃនេះ?**" "គោលបំណងវគ្គយើងគឺអ្វី?" **(ស្លាយទី២)**<br><br>**គោលបំណង** ៖ សិក្ខាកាមដែលជាគ្រូបឋមសិក្សា ឬមធ្យមសិក្សាទាំងអស់នឹងអាចដឹកនាំការបង្រៀនប្រកបដោយប្រសិទ្ធភាព និងសប្បាយរីករាយដោយឱ្យសិស្សអនុវត្តការងារគម្រោង និងក្តីបមុខវិជ្ជាតាមប្រធានបទពាក់ព័ន្ធ ដើម្បីបង្កើតនូវផលិតផលចុងក្រោយមួយដូចជា ខិតប័ណ្ណ កម្រងរូបភាព ថតសម្តែង បទបង្ហាញ ក្រាហ្វិក របាយការណ៍ ចងក្រងឯកសារ។ល។ ហើយសមិទ្ធផលនៃការអនុវត្តគម្រោងរបស់ពួកគេនឹងត្រូវបានធ្វើ បទបង្ហាញដល់អ្នកពាក់ព័ន្ធ ។<br><br>✓ សួរសិក្ខាកាមថា "**ដើម្បីសម្រេចបានតាមគោលបំណងខាងលើតើយើងត្រូវមានលទ្ធផលរំពឹងទុកអ្វីខ្លះពីសិក្ខាសាលារយៈពេល១ថ្ងៃនេះ?**" បង្ហាញលទ្ធផលរំពឹងទុក **(ស្លាយទី៣ និងទី៤)** | |

| គ្រូបង្រៀន | សិស្ស |
|---|---|
| ✓ ម្នាក់ៗមានផែនការការងារគម្រោង ។<br>✓ គ្រូម្នាក់ៗនឹងអនុវត្តការងារគម្រោងរបស់ខ្លួន ។<br>✓ គ្រូម្នាក់ៗអភិវឌ្ឍវិជ្ជាជីវៈរបស់ខ្លួនលើបច្ចេកទេសបង្រៀន ។<br>✓ គ្រូម្នាក់ៗមានបំណិនក្នុងការប្រើប្រាស់ឧបករណ៍ ICT | ✓ សប្បាយរីករាយក្នុងការសិក្សា។<br>✓ សិស្សមានជំនាញសិក្សាស្រាវជ្រាវ និងធ្វើបទបង្ហាញ<br>✓ អភិវឌ្ឍបំណិនទូទៅ និងមានឥរិយាបថសមស្រប ។ អនុវត្តការប្រើប្រាស់ឧបករណ៍ ICT ។ |

| | | | |
|---|---|---|---|
| | | ដែលមានស្រាប់ក្នុងសាលារៀនរបស់ខ្លួន ។<br><br>✓ សួរសិក្ខាកាមថា "**តើធ្វើដូចម្តេចដើម្បីឱ្យសម្រេចបានគោលបំណង និងលទ្ធផលរំពឹងទុកខាលើ?**" (ពិភាក្សាអំពីការចូលរួមរបស់សិក្ខាកាមនិងបទបញ្ជាផ្ទៃក្នុង)។<br>• ចូលរួមគ្រប់ការងារក្រុម (breakout rooms)<br>• ចូលរួមឆ្លើយសំណួរ និងផ្តល់យោបល់<br>• យកចិត្តទុកដាក់និងមានសំណួររាល់ចម្ងល់ | |
| | **២. តើរៀនដើម្បីអ្វី?** | ✓ បង្កើតព្យុះគំនិត ដោយឱ្យសិក្ខាកាមឆ្លើយនឹងសំណួរ "**តើរៀនដើម្បីអ្វី?**" រួចឱ្យសិក្ខាកាម ២ទៅ៣នាក់ឡើងឆ្លើយ។<br>✓ បន្ទាប់មកបង្ហាញ **(ស្លាយទី៥)**<br><br>ដើម្បីប្រឡងនិងបន្តការសិក្សាសិស្សរៀនបាន ៖<br>• ខ្លឹមសារ<br>• ទ្រឹស្តី<br>• រូបមន្ត<br><br>ដើម្បីជីវិតរស់នៅនិងការងារសិស្សរៀនបាន<br>• ការប្រើប្រាស់ចំណេះដឹងក្នុងការរស់នៅ និងអភិវឌ្ឍបំណិនចាំបាច់ក្នុងការរស់នៅ និងការងារ។<br>• ការស្វែងយល់ពីបរិស្ថានជុំវិញខ្លួន រួចសាទរនឹងវប្បធម៌ ប្រពៃណី ទំនៀមទម្លាប់និងការអនុវត្តល្អរបស់ខ្លួន ហើយកែលម្អចំណុចខ្វះខាត ។<br>• បង្កើតឱ្យមានកិច្ចសហការនិងសាមគ្គីល្អនៅក្នុងមូលដ្ឋាន។<br><br>✓ សំណួរភ្ជាប់ "**តើអ្នកត្រូវបង្រៀនសិស្សយ៉ាងដូចម្តេច?**" (ចម្លើយរំពឹងទុក ៖ បង្រៀនឱ្យសិស្សទទួលបាន **ការរៀនពិតប្រាកដ**)។ | |
| | **៣. តើអ្វីជាការរៀនពិតប្រាកដ?** | ✓ ឱ្យសិក្ខាកាមធ្វើការងារជាក្រុម មួយក្រុមមានគ្នា៣នាក់<br>• ហើយឱ្យពួកគាត់ឆ្លុះបញ្ចាំងលើការបង្រៀនរបស់ពួកគាត់ រយៈពេល៥នាទី។<br>• រួចសួរគាត់ថា "**តើការបង្រៀនរបស់ពួកគាត់ សិស្សទទួលបានការរៀនពិតប្រាកដដែររឺទេ?**" **ហេតុអ្វី?**<br>✓ បន្ទាប់មកចែកឯកសារឱ្យក្រុមនីមួយៗដែលអ្នកទី១ "វិធីដែលមនុស្ស | |

<table>
<tr>
<td></td>
<td></td>
<td>
រៀន" អ្នកទី២ "កត្តាមួយចំនួនដែលនាំឱ្យមានការរៀនពិតប្រាកដ" និងអ្នកទី៣ "ដំណើរការដែលនាំឱ្យមានការរៀនពិតប្រាកដ" រួចឱ្យគាត់អានជាបុគ្គល រយៈពេល១០នាទី។<br>
• បន្ទាប់មកក្នុងក្រុមនីមួយៗឱ្យសមាជិកម្នាក់ៗដែលបានអានឯកសារខុសៗគ្នាប្រាប់គ្នាម្តងម្នាក់ រយៈពេល១០នាទី។<br>
• រួចដឹកនាំពិភាក្សាលើឯកសារនីមួយៗ។<br>
• បន្ទាប់មកបង្ហាញ (ស្លាយទី៦) ដោយឱ្យក្រុមនីមួយៗឡើងបញ្ចេញយោបល់។<br>
✓ បង្ហាញអំពីសមិទ្ធផលដែលទទួលបានពីការរៀនពិតប្រាដក។ (ស្លាយទី៧)<br>
• ចំណេះដឹង ៖ ប្រធានបទជាក់លាក់ដែលគេបានអនុវត្ត ឬធ្វើការស្រាវជ្រាវដោយប្រើចំណេះដឹងគ្រប់មុខវជ្ជាដែលគេបានរៀនក្នុងថ្នាក់រៀន ក្រៅថ្នាក់រៀន (កុំព្យូទ័រ ថាប់ប្លេត ។ល។) ។<br>
• បំណិនទូទៅ ៖ ការប្រាស្រ័យទាក់ទង អន្តរបុគ្គល ការគិតដោយវិភាគ ការសម្រេចចិត្ត ការដោះស្រាយបញ្ហា ការបង្ហាញហេតុផលនិងភស្តុតាង ការធ្វើផែនការ ការសហការ ។ល។<br>
• ឥរិយាបថ ៖ ទំនុកចិត្តលើខ្លួនឯង ការឱ្យតម្លៃខ្លួនឯងនិងអ្នកដទៃ អធ្យាស្រ័យល្អ ភាពអំណត់ ភាពស្មោះត្រង់ ការទទួលខុសត្រូវនិងឥរិយាបថវិជ្ជមាន ។ល។<br>
✓ បង្ហាញរូបភាពផ្សេងៗនៃការរៀនដល់សិក្ខាកាមរួចសួរថា "តើការរៀនបែបនេះសិស្សអភិវឌ្ឍបានអ្វីខ្លះ?"។ (<u>ស្លាយទី៨</u>)<br>
• ឱ្យសិក្ខាកាមសរសេរចម្លើយក្នុងក្រដាស Sticker រួចយកទៅបិទលើក្តារខៀន។<br>
• បន្ទាប់មកធ្វើចំណាត់ថ្នាក់ចម្លើយទាំងនោះទៅតាមក្រុម រួចដាក់ឈ្មោះក្រុមទាំងនោះជាបី វិជ្ជាសម្បទា បំណិនសម្បទា ចរិយាសម្បទា។<br>
✓ សរុបសេចក្តីទៅការរៀនដោយឱ្យ "សិស្សធ្វើដោយផ្ទាល់" មិនត្រឹមតែធ្វើឱ្យពួកគេមានការចងចាំប៉ុណ្ណោះទេថែមទាំងជួយឱ្យគេអភិវឌ្ឍ បំណិននិងចរិយា ដែលជាតម្រូវការចាំបាច់ក្នុងការងារ និងរស់នៅផងដែរ។<br>
✓ បង្ហាញវីដេអូអំពីសមិទ្ធផលដែលសិស្សបានធ្វើ ។ (ស្លាយទី៩)
</td>
<td></td>
</tr>
</table>

| | | | |
|---|---|---|---|
| | | ✓ បន្ទាប់មក សួរសិក្ខាកាមថា តើសកម្មភាពសិស្សរៀនមានលក្ខណៈដូចម្ដេច? រួចប្រើបង្ហាញ (**ស្លាយទី១០**)<br>• ដូច្នេះដើម្បីឱ្យមានការរៀនពិតប្រាកដ គ្រូអាចប្រើយុទ្ធវិធីមួយក្នុងការបង្រៀនដោយរៀបចំ "**ការសិក្សាបែបគម្រោង ឬក្លឹបមុខវិជ្ជា**"។<br>• បន្ទាប់មកប្រាប់សិក្ខាកាមថាយើងនឹងរៀនពីធាតុរបស់វាយនៅពេលបន្តិចទៀតនេះ។ | |
| | **៤. តើការសិក្សាបែបគម្រោងជាអ្វី?** | ✓ សួរសិក្ខាថា "**តើអ្នកធ្លាប់ឮពាក្យគម្រោងដែរឬទេ**"? ឱ្យសិក្ខាកាមលើកឧទាហរណ៍រួចសរសេរលើក្ដារខៀន។ **៥នាទី**<br>• គម្រោងរៀបអាពាហ៍ពិពាហ៍<br>• គម្រោងសង់ផ្ទះ......<br>✓ បន្ទាប់មកបង្ហាញរូបភាពគំនិតខ្លះៗដើម្បីឱ្យសិក្ខាកាមមានគំនិត គិតពីការងារគម្រោង។ (**ស្លាយទី១១**)<br>✓ រួចសួរសិក្ខាកាមថា "**តើការងារគម្រោងជាអ្វី?**"<br>✓ បន្ទាប់មកបង្ហាញ (**ស្លាយទី១២**)<br><br>ការងារគម្រោងជាបទពិសោធន៍នៃការសិក្សាមួយ ដែលផ្ដល់ឱ្យសិស្ស នូវឱកាសដើម្បីសំយោគចំណេះដឹងពីផ្នែកផ្សេងៗនៃការសិក្សា រួចអនុវត្តវាទៅក្នុងស្ថានភាពរស់នៅប្រចាំថ្ងៃ ឬការស្រាវជ្រាវប្រកបដោយការវិភាគនិងច្នៃប្រឌិត។ ដំណើរការនេះជួយលើកកម្ពស់ចំណេះដឹងដល់សិស្សនិងអាចឱ្យពួកគេទទួលបានបំណិនជាច្រើនដូចជា ៖ បំណិនសហការណ៍ បំណិនប្រាស្រ័យទាក់ទង និងការរៀនដោយម្ចាស់ការព្រមទាំងរៀបចំពួកគេសម្រាប់ការរៀនមួយជីវិត និងត្រៀមខ្លួនក្នុងការប្រឈមនឹងឧបសគ្គនាពេលអនាគត។<br><br>✓ ចែកសិក្ខាកាមជាក្រុម៣ទៅ៤នាក់ (ប្រើលេខដើម្បីកំណត់សមាជិកក្រុម)<br>• ផ្ដល់បំពង់បឺតមួយបាច់និងស្កុតក្រដាសប្រវែង៣តឹក ស្មើៗគ្នាដើម្បីសង់អគារខ្ពស់មួយ។ បើក្រុមណាសង់បានខ្ពស់ | |

| | | | |
|---|---|---|---|
| | | និងទ្រទម្ងន់បានធ្ងន់ជាងគេ នោះក្រុមនោះជាអ្នកឈ្នះ។ **រយៈពេល១៥នាទី**<br>• ក្នុងករណីបណ្តុះបណ្តាលតាមប្រព័ន្ធអនឡាញ យើងអាចឱ្យសិក្ខាកាមមើលវីដេអូតាមតំណ អំពីការសង់អាគារដោយប្រើបំពង់បឺត **(ស្លាយទី១៣)**<br>✓ ពេលដែលសង់អគារ (ឬមើលវីដេអូ) ចប់ សួរសិក្ខាកាមថា ៖<br>• តើអ្នកមានអារម្មណ៍យ៉ាងដូចម្តេចដែរចំពោះសកម្មភាពនេះ?<br>• តើអ្នកបានរៀនអ្វីខ្លះពីសកម្មភាពនេះ?<br>• តើអ្នកបានធ្វើអ្វីខ្លះ ដើម្បីសង់អគារ?<br>✓ ទុកពេលឱ្យសិក្ខាកាមតាមក្រុមនីមួយៗពិភាក្សាថាតើគេបានធ្វើអ្វីខ្លះដើម្បីសង់អគាររបស់ពួកគេ។ សរសេរសកម្មភាពទាំងនោះលើក្រដាស Sticker រួចចំណាត់ថ្នាក់ចម្លើយទាំងនោះទៅតាមក្រុមដោយដាក់ឈ្មោះក្រុមទាំងនោះ ៖ **មុនពេលសាងសង់ កំពុងសាងសង់និងក្រោយពេលសាងសង់** ។ **១៥នាទី**<br>✓ រួចដឹកនាំពិភាក្សាក្រុមធំដោយទាញយកសេចក្តីសន្និដ្ឋានដូចខាងក្រោម ៖ **(ស្លាយទី១៤)**<br>• មុនពេលសាងសង់ = ការធ្វើផែនការ<br>• កំពុងសាងសង់ = ការអនុវត្តផែនការ<br>• ក្រោយសាងសង់ = ការវាយតម្លៃផែនការ<br>✓ ប្រាប់សិក្ខាកាមថា ការសាងសង់នេះជាការងារគម្រោងមួយ រួចសួរសិក្ខាកាមថា “**តើការងារគម្រោងជាអ្វី?**” ទុកពេលឱ្យសិក្ខាកាមគិតបន្តិច។ **៣នាទី**<br>ចម្លើយគឺ ៖ ការធ្វើផែនការ<br>ការអនុវត្តផែនការ<br>ការវាយតម្លៃផែនការ<br>**(សូមមើលក្នុងសៀវភៅមេរៀនទំព័រទី៩ “ការអភិវឌ្ឍការងារគម្រោង)**<br>✓ បន្ទាប់មកដឹកនាំសិក្ខាកាមទាំងអស់ពិភាក្សាគ្នាពីលទ្ធផលសិក្សារបស់សិស្សតាមរយៈការបង្រៀនតាមបែបការងារគម្រោង។ **(ស្លាយទី១៥)**<br>✓ ប្រាប់សិក្ខាកាមថា ដើម្បីអនុវត្តការងារគម្រោងបានជោគជ័យ | |

| | | | |
|---|---|---|---|
| | | យើងត្រូវ “**ធ្វើផែនការ  អនុវត្តផែនការ និងវាយតម្លៃផែនការ**”។<br>✓ បង្ហាញវីដេអូ ដែលសិស្សបានចូលរួមក្នុងកម្មវិធីការងារគម្រោងកន្លងមកនៃសាលារៀនជំនាន់ថ្មី។ (**ស្លាយទី១៦**)<br>• សួរសិក្ខាកាមថា “**តើអ្នកអាចបង្រៀនតាមបែបនេះពាក់ព័ន្ធនឹងមុខវិជ្ជារបស់អ្នកដែរឬទេ?**”។ | |
| | **៥.ប្រភេទនៃការងារគម្រោងនិងក្លឹបមុខវិជ្ជាដែលគ្រូអាចរៀបចំបាន** | ✓ សួរសិក្ខាកាមថា “**ឆ្លងកាត់តាមការសិក្សាកន្លងមកនេះ តើលោកគ្រូអ្នកគ្រូអាចរៀបចំការងារគម្រោងនិងក្លឹបសិក្សាអំពីអ្វីបានខ្លះ?**”<br>• ទុកពេលឱ្យសិក្ខាកាមគិតរយៈពេល**១០នាទី** ដោយសរសេរឈ្មោះការងារគម្រោងនិងក្លឹប រួចបិទនៅលើក្តារខៀន។<br>• ដឹកនាំពិភាក្សាទៅលើប្រធានបទនីមួយៗថាតើពួកគាត់អាចអនុវត្តបានឬអត់ (បើមិនមានប្រធានបទយកប្រធានបទទៅតាមឯកសារមេរៀន)។ **១០នាទី**<br>✓ បង្ហាញប្រធានបទដែលមានក្នុងឯកសារមេរៀន (**ស្លាយទី១៨**)<br>**អ្វីដែលមានស្រាប់ ៖** (**ស្លាយទី១៩ & ២០**)<br>✓ **ព្រឹត្តិការប្រវត្តិសាស្ត្រ** (ប្រាសាទដែលមានក្នុងមូលដ្ឋាន ទីកន្លែងប្រវត្តិសាស្ត្រ ឈ្មោះភូមិឬក៏ដកស្រង់ប្រធានបទក្នុងកម្មវិធីសិក្សា...) អាចធ្វើជាក្លឹបមុខវិជ្ជា។<br>✓ **វប្បធម៌ ប្រពៃណី** (របាំ សិល្បៈ បុណ្យទាន ឬក៏ដកស្រង់ប្រធានបទក្នុងកម្មវិធីសិក្សា...)។<br>✓ **របកគំហើញវិទ្យាសាស្ត្រ** (និយាយពីភព  និយាយពិការវិវឌ្ឍមនុស្ស សត្វ ជំងឺ ប្រព័ន្ធគ្រោងឆ្អឹងមនុស្ស សូរ្យគ្រាស ឬក៏ដកស្រង់ប្រធានបទក្នុងកម្មវិធីសិក្សា...)<br>✓ **រៀបចំពិសោធន៍វិទ្យាសាស្ត្រ** (គីមីវិទ្យា  រូបវិទ្យា...) អាចធ្វើជាក្លឹបមុខវិជ្ជា។<br>✓ **មេរៀនតាមមុខវិជ្ជាដែលមាននៅក្នុងកម្មវិធីសិក្សា** (ភាសាខ្មែរ/អង់គ្លេស ៖ អានអត្ថបទដោយប្រើល្បឿន បានត្រឹមត្រូវ  ការពន្យល់ពាក្យពិបាក  ការរកវេវចនសព្ទ...) អាចធ្វើជាក្លឹបមុខវិជ្ជា។<br>✓ **ប្រធានបទមួយចំនួនទៀតក្នុងឯកសារក្រសួងអប់រំ ក្នុងកម្មវិធី “បំណងប្រាថ្នា” ទំព័រទី៤ នៃឧបសម្ព័ន្ធបន្ថែម** | |

| | | | |
|---|---|---|---|
| | | **ហេតុការពិតឬបញ្ហាដែលជួបប្រទះប្រចាំថ្ងៃ ៖ (ស្លាយទី២១)**<br><br>✓ **សង្គម** (អំពើហិង្សាក្នុងគ្រួសារ ចំណាកស្រុក សុវត្ថិភាពចរាចរ ឥទ្ធិពលគ្រឿងញៀន ការរំលោភសិទ្ធកុមារ...)។<br>✓ **សុខភាព** (ការឆ្លងនិងបង្ការជំងឺគ្រុនឈាម ការឆ្លងនិងបង្ការជំងឺគ្រុនផ្តាសាយបក្សី អនាម័យខ្លួនប្រាណ ការប្រើប្រាស់គ្រឿងញៀន...)។<br>✓ **វិស័យអប់រំ** (មូលហេតុសិស្សខ្សោយអំណាននិងវិធីពង្រឹងអំណាន ផលប្រយោជន៍នៃការអានសៀវភៅ ផលប្រយោជន៍នៃការសិក្សា មូលហេតុនៃការអវត្តមានរបស់សិស្ស...)។<br><br>✓ មង្ហាញ **(ស្លាយទី ២២)** ប្រភេទគម្រោងទាំង៧ ដែលកំណត់ដោយក្រសួងអយក សម្រាប់ព្រឹត្តិការណ៍ "បំណងប្រាថ្នា"<br>✓ បន្ទាប់មក ប្រាប់សិក្ខាកាម ឱ្យមើលការពន្យល់លម្អិត អមដោយឧទាហរណ៍ប្រធានបទគម្រោងតាមមុខវិជ្ជា**ទំព័រទី៩-១៤** នៃឯកសារក្រសួងអយក សម្រាប់ព្រឹត្តិការណ៍ "បំណងប្រាថ្នា" ក្នុងឧបសម្ព័ន្ធបន្ថែម (ចំណាយពេល១៥នាទី ដើម្បីណែនាំ)<br>✓ បន្ទាប់មកទៀត សួរសិក្ខាកាមថា "**តើយើងអាចជ្រើសរើសយកប្រធានបទណាមួយក្នុងចំណោមខាងលើមកអនុវត្តបានទេ?**"<br>✓ ដើម្បីអនុវត្តការសិក្សាបែបគម្រោង **(ស្លាយទី ២៣)** សាលារៀនធ្វើការប្រជុំតម្រង់ទិសគ្រូបង្រៀនអំពីការសិក្សាបែបគម្រោង និងជំរុញការចូលរួមតាមរយៈ**ទម្រង់បង្ហាញពីចំណាប់អារម្មណ៍គ្រូបង្រៀន** ក្នុងឧបសម្ព័ន្ធទី២ ទំព័រទី៣២ (ចំណាយពេល៥នាទី ដើម្បីណែនាំ) | |
| | **៦. ការវាយតម្លៃការងារគម្រោងរបស់សិស្ស** | ✓ បង្ហាញស្លាយ **(ស្លាយទី២៤)**<br>✓ បន្ទាប់មកដឹកនាំពិភាក្សាចំណុចទី៦**ទំព័រទី១២** ក្នុងសៀវភៅមេរៀន។ | |
| | **៧. ការប្រៀបធៀបរវាងការងារគម្រោងនិងខ្លឹមមុខវិជ្ជា** | ✓ ដឹកនាំសិក្ខាកាមមើលចំណុចទី៧**ទំព័រទី១៣**ក្នុងឯកសារមេរៀន។ | |
| | **៨. ទស្សនៈទូទៅស្តីពីការបង្រៀនតាមទម្លាប់និងការបង្រៀនតាមបែបបង្កើតថ្មី** | ✓ ដឹកនាំសិក្ខាកាមមើលចំណុចទី៨ទំព័រ**ទី១៣និង១៤**ក្នុងឯកសារមេរៀន<br>• សួរសិក្ខាកាមថា "**តើយើងគួរអនុវត្តការបង្រៀនតាមទម្លាប់ឬការបង្រៀនតាមបែបបង្កើតថ្មី?**"។ | |

| | | | |
|---|---|---|---|
| | **៩. ការសិក្សាតាមបែបការងារគម្រោងនិងក្លឹបសិក្សានឹងជួយសិស្សអភិវឌ្ឍបំណិននៃការគិតស្របតាម** Bloom Taxonomy | ✓ ដឹកនាំសិក្ខាកាមមើលចំណុចទី៩ទំព័រទី១៤និង១៥ក្នុងឯកសារមេរៀន<br>✓ បន្ទាប់មកបង្ហាញ **(ស្លាយទី២៥)** | |
| | **១០. ការធ្វើផែនការចំពោះការងារគម្រោងរបស់អ្នក** | ✓ សួរសិក្ខាកាមថា<br>• តើអ្នកធ្លាប់ធ្វើផែនការដែរឬទេ?<br>• តើវាមានធាតុសំខាន់នៃផែនការអ្វីខ្លះ?<br>✓ សរសេរចម្លើយលើក្ដាខៀនរួចសួរថា “**តើផែនការនេះមានលក្ខណៈគ្រប់ជ្រុងជ្រោយដែរឬទេ?**” ដូច្នេះបើវាមានលក្ខណៈគ្រប់ជ្រុងជ្រោយ “**តើវាមានរូបរាងដូចម្ដេច?” (ស្លាយទី២៦)**<br>• ការកំណត់គោលបំណង/ផលិតផលចុងក្រោយ (ចាប់ផ្ដើមគិតមុនគេ)។<br>• សកម្មភាព/រយៈពេល/ធនធាន (លម្អិតសកម្មភាពជាដំណាក់ៗ)។<br>• វាយតម្លៃ (ធៀបទៅនឹងគោលបំណង/ផលិតផលចុងក្រោយ)<br>✓ ប្រាប់សិក្ខាកាមថា ការងារគម្រោងបានជោគជ័យតម្រូវឱ្យមានផែនការមួយច្បាស់លាស់ ការអនុវត្តដោយភាពច្នៃប្រឌិតនិងការវាយតម្លៃនៅចុងបញ្ចប់។<br>✓ ដឹកនាំសិក្ខាកាមមើលចំណុក “ក ខ គ” ក្នុងសៀវភៅមេរៀនទំព័រទី១៥ ១៦ ១៧ និង១៨។ និង ដឹកនាំសិក្ខាកាមមើលគំរូផែនការគម្រោង ក្នុងឧបសម្ព័ន្ធទី១ក, ១ខ និង ១គ។ (ចំណាយពេល ៣០ នាទី) | |
| | លំហាត់អនុវត្ត | ✓ ចែកសិក្ខាកាមជាក្រុម ៤ទៅ៥នាក់។<br>✓ ក្រុមនីមួយៗជ្រើរើសប្រធានបទណាមួយដែលខ្លួនពេញចិត្ត។ (គោលបំណង/ផលិតផលចុងក្រោយ)<br>✓ អនុវត្តសកម្មភាពការងារគម្រោង។ (សកម្មភាព/រយៈពេល/ធនធាន)<br>✓ ឡើងបង្ហាញពីអ្វីដែលក្រុមស្រាវជ្រាវបាន។ (ការវាយតម្លៃផែនការ) | |
| | | ✓ ការវាយតម្លៃសិក្ខាសាលា ដោយប្រើឧបករណ៍ខាងក្រោម។ | |
| | | ✓ បិទកម្មវិធីបំប៉ន | |

# ឧបករណ៍វាយតម្លៃសិក្ខាសាលា

សូមឆ្លើយនឹងសំណួរដូចខាងក្រោមដោយស្មោះត្រង់បំផុត។ វាជាការសម្ងាត់ដោយមិនតម្រូវឱ្យអ្នកដាក់ឈ្មោះ ឡើយ។ ការវាយតម្លៃនេះនឹងត្រូវយកទៅប្រើប្រាស់ដើម្បីលើកកម្ពស់ការរៀបចំសិក្ខាសាលានាពេលខាងមុខឱ្យបានប្រសើ។ សូមថ្លែងអំណរគុណទុកជាមុនចំពោះការយកចិត្តទុកដាក់របស់លោកអ្នក ក្នុងការបំពេញឧបករណ៍វាយតម្លៃនេះ។

១. តើអ្វីខ្លះដែលអ្នកពេញចិត្ត ក្នុងសិក្ខាសាលារយៈពេល១ថ្ងៃនេះ?

..........................................................................................................................

..........................................................................................................................

..........................................................................................................................

២. តើអ្វីខ្លះដែលអ្នកមិនពេញចិត្ត ក្នុងសិក្ខាសាលារយៈពេល១ថ្ងៃនេះ?

..........................................................................................................................

..........................................................................................................................

..........................................................................................................................

៣. តើអ្នកទទួលបានចំណេះដឹងអ្វីខ្លះពីសិក្ខាសាលារយៈពេល១ថ្ងៃនេះ? (មិនមែនចំណងជើងមេរៀន ឬសកម្មភាពដែលយើងបានរៀនឡើយ តែវាជាចំណេះដឹងដែលអ្នកទទួលបាន)

..........................................................................................................................

..........................................................................................................................

..........................................................................................................................

៤. តើអ្នកគិតថាវិធីសាស្ត្របង្រៀនតាមរបៀបការសិក្សាបែបគម្រោងនេះ សិស្សនឹងទទួលបានបំណិនអ្វីខ្លះ?

..........................................................................................................................

..........................................................................................................................

..........................................................................................................................

៥. ឆ្លងកាត់តាមរយៈវគ្គបំប៉ននេះហើយ តើអ្នកគិតថាអាចដឹកនាំការបង្រៀនសិស្សតាមរបៀបការងារគម្រោងបានដែរឬទេ?

..........................................................................................................................

..........................................................................................................................

..................................................................................................................................

៦. បន្ទាប់ពីសិក្ខាសាលានេះ តើអ្នកនឹងធ្វើអ្វី?

..................................................................................................................................

..................................................................................................................................

..................................................................................................................................

៧. ជារួម តើអ្នកឱ្យតម្លៃសិក្ខាសាលានេះកម្រិតណា? (កម្រិតពី១ទៅ៥ ។ ១អាក្រក់បំផុតនិង៥ល្អបំផុត)។

១ ២ ៣ ៤ ៥

៨. យោបល់ផ្សេងៗ

..................................................................................................................................

..................................................................................................................................

........................................................................................................................